# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1633

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : ការសាងសង់អគារស្នាក់នៅរបស់និស្សិតនៅវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/25

កាលបរិច្ឆេទបញ្ចប់គម្រោង 01/01/25

៣. ចំណាយគម្រោងសរុប $1,250,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

RESPONSIBLE UNIT Prek Leap National Institute of Agriculture

អង្គភាពទទួលខុសត្រូវ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

៥. ស្ថានភាពគម្រោង គម្រោងកំពុងដំណើរការ

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ បញ្ចូលក្នុងវាំងថវិការ និងឥណទានផ្សេងៗ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី១- ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

រួមចំណែកពង្រឹងសុខមភាពនិស្សិត និងគុណភាពអប់រំនៅវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? គាំទ្រ

១១. វិស័យ ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

ការអប់រំ

Higher Education

Higher Education

Higher Education

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

រាជធានីភ្នំពេញ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

១) កែលម្អស្ថានភាពរស់នៅរបស់និស្សិតឲ្យកាន់តែប្រសើរឡើង ដែលរួមមាន សុខភាព និងសុវត្ថិភាព ជាពិសេសសម្រាប់និស្សិតស្រី
២) ដើម្បីរួមចំណែកកែលម្អគុណភាពអប់រំ ដោយអនុញ្ញាតឲ្យនិស្សិតមានកន្លែងទូលាយសម្រាប់សិក្សាបន្ថែមនៅក្នុងបន្ទប់ពួកគេ
៣) និស្សិតអាចកាត់បន្ថយការចំណាយលើការជួលបន្ទប់ ព្រោះតម្លៃជួលបន្ទប់ក្នុងសាលាថោកជាង និងមានសុវត្ថភាពជាងជួលបន្ទប់ខាងក្រៅវិទ្យាស្ថាន
៤) វិទ្យាស្ថានក៏អាចរកចំណូលបន្ថែមតាមរយៈជួលបន្ទប់ឲ្យនិស្សិត និងធានាបានសុវត្ថភាពសម្រាប់និស្សិត។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

វិទ្យាស្ថានស្ថានជាតិកសិកម្មព្រែកលៀប ត្រូវបានបង្កើតឡើងតាំងឆ្នាំ១៩៤៨ ជាដំបូងគឺជាស្ថានីយ៍ពិសោធន៍ពូជពោតក្រហម។ ដូច្នេះមកទល់ពេលនេះមានអាយុកាល ៧៥ ឆ្នាំហើយ ដែលជាស្ថានប័នពាក់ព័ន្ធនឹងការបណ្តុះបណ្តាល និងស្រាវជ្រាវផ្នែកកសិកម្ម។ បច្ចុប្បន្នវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប បាននិងកំពុងបណ្តុះបណ្តាលថ្នាក់បរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងមានគម្រោងបើកថ្នាក់បណ្ឌិតដើមឆ្នាំ២០២៥នេះ។ ជាមួយគ្នានេះ វិទ្យាស្ថានមាននិស្សិតប្រមាណ ១៤០០ នាក់កំពុងសិក្សាក្នុងឆ្នាំសិក្សា ២០២៤-២០២៥ ដែលមានការកើនឡើងប្រហែល ១០% ក្នុងរយៈពេល៥ ឆ្នាំចុងក្រោយនេះ។ បើទោះបីមកទល់ពេលនេះ វិទ្យាស្ថាន មានអន្តេវាសិកដ្ឋានមួយកន្លែងក៏ដោយ ប៉ុន្តែអាចឲ្យនិស្សិតស្នាក់នៅបានតែ១០០ នាក់ប៉ុណ្ណោះ ហើយអគារទៀតមានលក្ខណៈចាស់ទ្រុតទ្រោម គ្មានអនាម័យ។ ដូច្នេះការបង្កើតអន្តេវាសិកដ្ឋានថ្មី វាចាំបាច់បំផុតសម្រាប់តម្រូវការស្នាក់នៅរបស់និស្សិតដែលចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ គម្រោងនេះចែកចេញជាពីរ ផ្នែក គឺផ្នែកទី១ មានថវិកា ៦២ ៥០០ ដុល្លា សម្រាប់សាងសង់ឆ្នាំទី១ (២០២៥) និងផ្នែកទី២ (ឆ្នាំ២០២៦) មានថវិកា ៦២ ៥០០ ដុល្លា។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

បច្ចុប្បន្នវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប បាននិងកំពុងបណ្តុះបណ្តាលថ្នាក់បរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងមានគម្រោងបើកថ្នាក់បណ្ឌិតនៅក្នុងខែមេសា២០២៥នេះ។ ជាមួយគ្នានេះ វិទ្យាស្ថានមាននិស្សិតប្រមាណ ១៤០០ នាក់កំពុងសិក្សា ដែលមានការកើនឡើងប្រហែល ១០% រាល់ឆ្នាំក្នុងរយៈពេល៥ ឆ្នាំចុងក្រោយនេះ។ និស្សិតសិក្សានៅវិទ្យាស្ថាន ប្រមាណ៨០% ជាអ្នកមកពីខេត្ត និងភាគច្រើនមានជីវភាពក្រីក្រ។ មកទល់ពេលនេះបើទោះបីជាវិទ្យាស្ថានមានកន្លែងឲ្យនិស្សិតស្នាក់នៅបានខ្លះៗក៏ដោយ ប៉ុន្តែមិនបានឆ្លើយតបតាមការស្នើសុំរបស់និស្សិតនៅឡើយ ព្រោះចំនួនបន្ទប់មានកំណត់។ ជាងនេះទៅទៀតអគារស្នាក់នៅរបស់និស្សិតមានអាយុចាស់ណាស់ទៅហើយ មិនមានអនាម័យគ្រប់គ្រាន់ ដោយមួយបន្ទប់និស្សិតស្នាក់នៅរហូតដល់៥ ទៅ៦ នាក់។ ការស្នាក់នៅច្រើននាក់ក្នុងបន្ទប់តែមួយដូច្នេះ មិនមានលក្ខណៈល្អប្រសើ សម្រាប់ការសិក្សា និងសុវត្ថិភាពរបស់និស្សិតឡើយ ជាពិសេសសម្រាប់និស្សិតស្រី។

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

**១) និស្សិតនឹងអាចរស់នៅមានផាសុខភាព និងមានសុវត្ថិភាពល្អ**

**២) គុណភាពសិក្សារបស់និស្សិតកាន់តែប្រសើរឡើង**

**៣) បានជួយសម្រាលការចំណាយរបស់និស្សិត ក៏ដូចជាការរួមចំណែកកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា**

**៤) និស្សិតកាន់តែច្រើននឹងជ្រើសរើសការសិក្សានៅវិទ្យាស្ថានជាតិកសិកម្មព្រែក ដោយសារមានកន្លែងស្នាក់នៅសមរម្យ និងសុវត្ថិភាព។**

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **ត្រូវបានរៀបចំ**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងសាងសង់អគារស្នាក់របស់និស្សិត នឹងផ្តល់ផលប្រយោជន៍ជាច្រើនទាំងរយៈពេលខ្លីនិងវែងដល់ សេដ្ឋកិច្ច បរិស្ថាន និងសង្គម ដែលរួមមាន៖**

**១) និស្សិតចំណាយតិចជាងមុន ហើយវិទ្យាស្ថានបានទទួលផលប្រយោជន៍ច្រើនជាងមុន ដោយសារអគារស្នាក់នៅអាចផ្ទុកនិស្សិតបានច្រើនជាងមុន**

**២) បរិស្ថាននៃការស្នាក់នៅរបស់និស្សិតបានប្រសើរជាងមុន។ ជាមួយគ្នានេះបរិស្ថាននៅជុំវិញអគារក៏ប្រសើរជាងមុន។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **១៨. ជីវភាពរស់នៅ (ទូទៅ)** | 30 | **ទាក់ទងតិចតួច** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការកាត់បន្ថយ**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**ពីមុនការស្នាក់នៅរបស់និស្សិតស្រី មានហានិភ័យ ដោយសារបន្ទប់តូចចង្អៀត ហើយស្នាក់នៅ៥ ទៅ៦នាក់។ ជាងនេះទៅទៀតអគារស្នាក់នៅពីមុន មិនរឹងមាំ និងធ្លុះធ្លាយ មិនមានសុវត្ថិភាពដល់និស្សិតស្រីឡើយ។ អគារសង់ថ្មី នឹងផ្តល់ សុវត្ថិភាព អនាម័យ និងឱកាសការសិក្សាបន្ថែមទៀតដល់និស្សិតស្រី។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

គម្រោងត្រូវគាំទ្រដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសម្រេចផ្តល់ថវិកាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២៣. [illegible] បណ្តាល ឲ្យមាន ការពន្យាពេលក្នុងការអនុវត្តគម្រោង។)

មកទស់ខែមករា ឆ្នាំ២០២៥ នេះ វិទ្យាស្ថានបានចាប់ផ្តើមរុះរើអគារចាស់ចេញ។ ពេលចប់រុះរើ ការសាងសង់អគារថ្មីនឹងចាប់ផ្តើម ដែលរំពឹងនឹងចាប់ផ្តើមក្នុងខែមីនា ២០២៥។

២៤. **អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

2

២៥. **ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

អ្នកផ្តល់ថវិកាសម្រាប់អនុវត្តគម្រោងសាងសង់អន្តេវាសិកដ្ឋាននិស្សិតនេះ ទ្រទ្រង់ថវិកាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (៦០%) និងថវិកាបរិភាគរបស់វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប (៤០%)។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 10,000.0 | 12,000.0 | 22,000.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 1,250,000.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 750,000.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 500,000.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 1,250,000.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | -1,250,000.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: